# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ១០

## សុវត្ថិភាព និង សុខុមាលភាពវិជ្ជាជីវៈ
## “សុវត្ថិភាពនៅការដ្ឋានដោះមីន”

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


មាតិកា ........................................ ២
សេចក្ដីផ្ដើម ........................................ ៤
សុវត្ថិភាព និងសុខុមាលភាព-សុវត្ថិភាពការដ្ឋានដោះមីន ........................................ ៥
១.ទ្រង់ទ្រាយ ........................................ ៥
២.តម្រូវការទូទៅ ........................................ ៥
៣.នីតិវិធី និង ការរៀបចំការដ្ឋានដោះមីន ........................................ ៥
៣.១.តម្រូវការទូទៅ ........................................ ៥
៣.២. ការដាក់សញ្ញាសំគាល់តំបន់គ្រោះថ្នាក់ ........................................ ៥
៣.៣. ត្រួតពិនិត្យការចូលទៅកាន់តំបន់គ្រោះថ្នាក់ដោយមីនខ្យល់ ឬ តំបន់មីនជះអំបែង ........................................ ៦
៣.៤. តំបន់ត្រួតពិនិត្យ ........................................ ៨
៣.៤.១. កន្លែងចតរថយន្ត ........................................ ៨
៣.៤.២. កន្លែងចុះចតឧទ្ធម្ភាគចក្រ ........................................ ៨
៣.៤.៣. កន្លែងពន្យល់សង្ខេប និងរាយការណ៍ជូនភ្ញៀវ ........................................ ៩
៣.៤.៤. បរិក្ខារការពារខ្លួន ........................................ ៩
៣.៤.៥. ផ្លូវសុវត្ថិភាព ........................................ ៩
៣.៤.៦. ការសង្គ្រោះបឋម ........................................ ៩
៣.៤.៧. កន្លែងឈប់សំរាក ........................................ ៩
៣.៤.៨. កន្លែងទុកដាក់គ្រឿងផ្ទុះនៅការដ្ឋាន ........................................ ១០
៤.ឧប្បទ្ទវហេតុ និងគ្រោះថ្នាក់ដោះមីន ........................................ ១១
៥.កាតព្វកិច្ច និងការទទួលខុសត្រូវ ........................................ ១១
៥.១. អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ........................................ ១១
៥.២. ប្រតិបត្តិករដោះមីន ........................................ ១១
៥.៣. អ្នកដោះមីន ........................................ ១២
ឧបសម្ព័ន្ធក (ជាធម្មតា)ចំងាយសុវត្ថិភាពសំរាប់មីនខ្យល់ និងមីនជះអំបែង ........................................ ១៣
១.ទូទៅ ........................................ ១៣
២.ការកំណត់ចំងាយសុវត្ថិភាព ........................................ ១៣
២.១. ការកំណត់ចំងាយសុវត្ថិភាពនៅការដ្ឋានដោះមីន ........................................ ១៣
២.២. ការកំណត់ចំងាយសុវត្ថិភាពនៅការដ្ឋានដោះមីន ........................................ ១៤
ឧបសម្ព័ន្ធខ (ជាពត៌មាន) ចំពោះភ្ញៀវដែលមកទស្សនៈកិច្ចការដ្ឋានដោះមីន ........................................ ១៥
១.ជាទូទៅ ........................................ ១៥
២.បទដ្ឋានប្រតិបត្តិការ ........................................ ១៥
៣.ការជានារ៉ាប់រង ........................................ ១៥

# សេចក្ដីផ្ដើម

តម្រូវការនានាដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងផ្ដល់បរិយាកាសនៃសុវត្ថិភាពការងារ គឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងសកម្មភាពកំចាត់មីន (សូមអានស្តង់ដា០៧.១០)។ ការកាត់បន្ថយគ្រោះថ្នាក់ ទាក់ទងនឹងការអនុវត្តន៍ការងារប្រកបដោយសុវត្ថិភាព នីតិវិធីប្រតិបត្តិការប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ ការអប់រំ និងការបណ្តុះបណ្តាលសមស្រប ការប្រើប្រាស់សំភារៈដែលបានរៀបចំឡើងប្រកបដោយសុវត្ថិភាព និងបញ្ញត្តិនៃការប្រើប្រាស់បរិក្ខារការពារខ្លួន។

បរិយាកាសការងារប្រកបដោយសុវត្ថិភាព រាប់បញ្ចូលទាំងការធ្វើគំពោង និងការរៀបចំការដ្ឋានដោះមីន ដោយការព័ទ្ធរបង និងការដាក់សញ្ញាសំគាល់តំបន់គ្រោះថ្នាក់ ការត្រួតពិនិត្យចលនាអ្នកដោះមីន ភ្ញៀវ និងសាធារណៈជនការជុំរុញការអនុវត្តន៍ចំងាយសុវត្ថិភាព ការផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធភាព និងការធានារ៉ាប់រង។ ចំណុចនេះតម្រូវអោយអាជ្ញាធរមីន និងប្រតិបត្តិករដោះមីនបង្កើតការថែរក្សាច្បាប់ និងនីតិវិធីសមស្រប។

ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវអត្ថន័យរបស់ពាក្យ "សុវត្ថិភាព" នៅក្នុងសកម្មភាពកំចាត់មីន។ ដើម្បីនិយាយថា ស្ថានការណ៍មួយមានសុវត្ថិភាព មិនមានន័យថាគ្រោះថ្នាក់ទាំងអស់ត្រូវបានយកចេញនោះទេ។ តែវាជាការកាត់បន្ថយគ្រោះថ្នាក់នោះឲ្យដល់កំរិតមួយដែលអាចទទួលយកបាន ដោយផ្អែកលើការវាយតំលៃនៃសង្គមបច្ចុប្បន្ន។ (សូមអានការណែនាំ ISO លេខ៥១)

ដោយសង្កេតឃើញថាកិច្ចប្រតិបត្តិការសកម្មភាពដោះមីននៅក្នុងប្រទេសកម្ពុជាមានលក្ខណៈធំធេង គេមិនអាចផ្តល់នូវសេចក្តីបញ្ជាក់ទាំងស្រុង ត្រឹមត្រូវឥតខ្ចោះបានគ្រប់ការដ្ឋានដោះមីនឡើយ។ ដូចនេះ ប្រតិបត្តិករដោះមីនគួរបង្កើត និងថែរក្សានីតិវិធី និងកិច្ចដំណើរការ ដែលអាចផ្តល់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈ តាមរយៈការកំណត់នូវកំរិតគ្រោះថ្នាក់ ការវាយតំលៃ និងកាត់បន្ថយគ្រោះថ្នាក់នោះទៅតាមប្រព័ន្ធមួយដែលសមស្រប និងទាន់ពេលវេលា។

ស្តង់ដានេះ ផ្តល់នូវការណែនាំពីការរៀបចំបង្កើត និងការអនុវត្តន៍គោលនយោបាយ និងឯកសារនីតិវិធីសំរាប់បង្កើត និងគ្រប់គ្រងការដ្ឋានប្រកបដោយសុវត្ថិភាព។

# សុវត្ថិភាព និង សុខុមាលភាព
# សុវត្ថិភាពការដ្ឋានដោះមីន

## ១.ទំហំវិសាលភាព

ស្តង់ដានេះផ្តល់សេចក្តីបញ្ជាក់ច្បាស់លាស់ និងការណែនាំពីការបង្កើត ការអនុវត្តន៍គោលនយោបាយ ឯកសារនីតិវិធី និងការងារសំរាប់បង្កើត ការរក្សាការដ្ឋានដោះមីន និងបរិយាកាសការងារមួយប្រកបដោយសុវត្ថិភាព។

## ២.តម្រូវការទូទៅ

បញ្ញត្តិនៃបរិយាកាសការងារមួយប្រកបដោយសុវត្ថិភាព រាប់បញ្ចូលទាំងការធ្វើគំរោងនិងការរៀបចំការដ្ឋានដោះមីនដោយការព័ទ្ធរបង និងដាក់សញ្ញាសំគាល់តំបន់គ្រោះថ្នាក់ ការត្រួតពិនិត្យចលនាអ្នកដោះមីន ភ្ញៀវ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ការជុំរុញការអនុវត្តន៍ចំងាយសុវត្ថិភាព និងការប្រើប្រាស់បរិក្ខារការពារខ្លួនគ្រប់ពេលដែលបំពេញការងារនៅកន្លែងគ្រោះថ្នាក់ ព្រមទាំងការផ្តល់ការព្យាបាល និងនីតិវិធីជំលៀសជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។ ចំណុចនេះ តម្រូវអោយអាជ្ញាធរមីន និងប្រតិបត្តិករដោះមីនចងក្រងជាច្បាប់ និងរក្សានីតិវិធីសំរាប់សុវត្ថិភាពការដ្ឋាន។

## ៣.ការរៀបចំការដ្ឋានដោះមីន និងនីតិវិធី

### ៣-១- តម្រូវការទូទៅ

ការដ្ឋានដោះមីនត្រូវរៀបចំសំរាប់៖

ក. បង្ហាញឲ្យឃើញច្បាស់នូវការបែងចែកតំបន់គ្រោះថ្នាក់ រាប់បញ្ចូលទាំងតំបន់គ្រោះថ្នាក់ដោយអំបែង តំបន់បោសសំអាតមីនរួច តំបន់ដែលអាចប្រើប្រាស់បាន និងតំបន់មិនស្គាល់នៅជុំវិញការដ្ឋាន

ខ. ត្រួតពិនិត្យចលនាអ្នកដោះមីន និងភ្ញៀវ(រាប់បញ្ចូលសមាជិកផ្សេងទៀត)នៅការដ្ឋាន

គ. កំណត់ចំនួនអ្នកដោះមីន និងភ្ញៀវដែលត្រូវអនុញ្ញាត្តិអោយចូលទៅកាន់តំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង

ឃ. នៅពេលធ្វើការកំទេចមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវចាត់វិធានការណ៍ចាំបាច់នានា ដែលអាចធ្វើទៅបានដើម្បីជំលៀសអ្នកដោះមីន ភ្ញៀវ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ចេញពីតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង ឬផ្តល់នូវការការពារសមស្រប ដោយអោយចូលទៅក្នុងអាគារ លេណដ្ឋាន និងរចនាសម្ព័ន្ធចល័តផ្សេងទៀត

ង. ដាក់បញ្ចូលនូវវិធានការទប់ស្កាត់ការធ្វើអោយខូចខាតរចនាសម្ព័ន្ធ និងបរិស្ថាន

### ៣-២- ការដាក់សញ្ញាសំគាល់តំបន់គ្រោះថ្នាក់

ត្រូវខ័ណ្ឌចែកឲ្យដាច់ពីគ្នានូវតំបន់សុវត្ថិភាព និងតំបន់គ្រោះថ្នាក់នៅក្នុងការដ្ឋាន ដោយការដាក់សញ្ញាសំគាល់អោយបានច្បាស់លាស់ និងជាប់លាប់។ (សូមអានស្តង់ដា ០៨.៤០)

### ៣-៣- ការត្រួតពិនិត្យការចូលទៅក្នុងតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ ឬមីនជះអំបែង

ជានិច្ចកាលការដោះមីនគឺជាព្រឹត្តិការណ៍ដែលគួរអោយចាប់អារម្មណ៍សំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ពិសេសកុមារ។ ត្រូវរៀបចំនីតិវិធីចាំបាច់នានា ដើម្បីត្រួតពិនិត្យការចូលនៃអ្នកដែលគ្មានការអនុញ្ញាត ទៅកាន់តំបន់គ្រោះថ្នាក់ដោយសារមីន ឬគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការដ្ឋានដោះមីន និងតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង។

**ការងារនេះអាចសំរេចបានតាមរយៈ**

ក. ការជូនដំណឹងដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន អ្នកដោះមីន និងភ្ញៀវទស្សនៈកិច្ចការដ្ឋានដោះមីនពីទំហំនៃការដ្ឋានដោះមីន និងតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង

ខ. ការត្រួតពិនិត្យដោយផ្ទាល់ពីការចូលទៅកាន់តំបន់គ្រោះថ្នាក់ ក្នុងអំឡុងពេលកំទេចមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដោយដាក់សញ្ញាហាមឃាត់ និងប៉ុស្តិ៍យាមកាម (សូមអានឧប្បសម្ព័ន្ធក ស្តីពីការបញ្ជាក់ និងអនុសាសន៍នានាស្តីពីការបង្កើតស្តង់ដា និងបទដ្ឋានប្រតិបត្តិការសំរាប់ចំងាយសុវត្ថិភាពនៃតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង)

**ចំណាំ១**:ប្រព័ន្ធព្រមាន ត្រូវដាក់បញ្ចូលនូវព័ត៌មានដូចខាងក្រោម:

- ការដាក់ផ្លាកសញ្ញាហាមឃាត់នៅផ្លូវចេញចូល (ផ្លូវថ្នល់ ផ្លូវរទេះគោ ឬផ្លូវលំ) ដើម្បីជូនដំណឹងដល់ប្រជាជនដែលកំពុងចូលមកកាន់តំបន់គ្រោះថ្នាក់ដោយអំបែងមីន/គ្រាប់។ សញ្ញាទាំងអស់នោះ ត្រូវដាក់បញ្ចូលពត៌មានពីសភាព និងទំហំនៃតំបន់គ្រោះថ្នាក់នៃតំបន់ជះអំបែង។
- ការអប់រំកាត់បន្ថយគ្រោះថ្នាក់ត្រូវធ្វើឡើងតាមរយៈការពន្យល់សង្ខេប ឬការដាក់ផ្លាកសញ្ញា ឬពត៌មានដែលត្រូវផ្តល់អោយប្រជាជនដែលរស់នៅ ឬធ្វើការងារនៅក្បែរការដ្ឋានដោះមីន និងអាជ្ញាធរដែនដីក្នុងតំបន់។ ការពន្យល់សង្ខេប និង/ឬក្រដាសផ្សព្វផ្សាយ គួរបញ្ចូលទាំងពត៌មានពីវិធីសាស្ត្រនៃការព្រមានដោយប្រើឧបករណ៍បំពងសំលេង និងការពិនិត្យមើលផ្ទាល់ភ្នែក ដើម្បីធ្វើការណែនាំកម្មករ និងប្រជាជននៅក្នុងមូលដ្ឋានអំពីការកំទេចមីន/គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសំភារៈគ្រោះថ្នាក់ផ្សេងៗទៀត។
- ការអប់រំកាត់បន្ថយគ្រោះថ្នាក់ រាប់បញ្ចូលទាំងកន្លែងគ្រោះថ្នាក់នានា និងការជាប់ទាក់ទងពីការមិនដឹងមិនឮនៃការណែនាំដល់អ្នកដោះមីន ដែលបានចាត់តាំងអោយត្រួតពិនិត្យផ្លូវចេញ-ចូលនៅតំបន់គ្រោះថ្នាក់។
- ឯកសារស្តង់ដា និងបទដ្ឋានប្រតិបត្តិការ ត្រូវដាក់បញ្ចូលការប្រើប្រាស់ប៉ុស្តិ៍យាម ដើម្បីត្រួតពិនិត្យការចូលទៅកាន់តំបន់គ្រោះថ្នាក់ ផ្លាកសញ្ញា និងការផ្តល់សញ្ញាតាមរយៈការប្រើឧបករណ៍បំពងសំលេង ដែលត្រូវប្រើក្នុងពេលដំណើរការកំទេចមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ការធ្វើផែនការ និងការប្រតិបត្តិការងារដោះមីន ត្រូវកាត់បន្ថយការរំខានដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលធ្វើដំណើរឆ្លងកាត់តំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែង។ ជាការពិតណាស់យើងមិនអាចទប់ស្កាត់សាធារណៈជន មិនអោយចូលទៅកាន់តំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និងមីនជះអំបែងក្នុងអំឡុងពេលធ្វើការដោះមីនទាំងស្រុងបានឡើយ។ ម្យ៉ាងទៀត ចាំបាច់ត្រូវកាត់បន្ថយគ្រោះថ្នាក់នេះដល់កំរិតមួយដែលអាចទទួលយកបាន ដើម្បីកុំឲ្យបង្កការឈឺចាប់ដល់សាធារណៈជន។ ឧទាហរណ៍ខាងក្រោម អាចផ្តល់ជាការណែនាំស្តីពីការបង្កើតកន្លែងធ្វើការមួយដែលមានលក្ខណៈសមរម្យ:

គ. វិសាលភាពនៃតំបន់ជះអំបែង គួរមានទំហំស្មើគ្នាទៅនឹងតំបន់គ្រោះថ្នាក់ដោយសារអំបែងមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងការដ្ឋាន។

ឃ.ដោយបានផ្តល់សញ្ញាព្រមានដូចដែលបានរៀបរាប់ខាងលើ សាធារណៈជនគួរត្រូវបានអនុញ្ញាតអោយឆ្លងកាត់ តំបន់គ្រោះថ្នាក់ដោយអំបែង តាមផ្លូវដែលមានដាក់ផ្លាកសញ្ញាច្បាស់លាស់ លើកលែងតែពេលកំពុងធ្វើការកំទេចគ្រាប់។ នៅពេលធ្វើការកំទេចគ្រាប់ ប្រតិបត្តិករដោះមីនត្រូវបង្កើតប៉ុស្តិ៍យាមនៅដើមផ្លូវចូល ដើម្បីការពារការចូលនៃសាធារណៈជនទៅកាន់តំបន់គ្រោះថ្នាក់ ដោយបំពាក់គ្រប់គ្រាន់នូវមធ្យោបាយទំនាក់ទំនង ឬឲ្យសញ្ញាគ្នានៅមាត់ច្រកចេញ-ចូលទៅកាន់តំបន់គ្រោះថ្នាក់នោះ។ ត្រូវធ្វើការយាមកាមឲ្យបានតឹងរឹងបំផុត នៅពេលមានការកំទេចប្រភេទមីនលោតជះអំបែង និងគ្រាប់ដែលមានអំបែងច្រើន។

ង. ចំងាយសុវត្ថិភាពខាងក្នុងត្រូវកំណត់ឲ្យច្បាស់លាស់។ ឧទាហរណ៍: តំបន់នៃកាំរង្វង់មីនជះខ្យល់ពីកន្លែងមានមីន ឬគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការបែងចែកផ្លូវបោសសំអាត ឬគ្រោះថ្នាក់នៃគីបផ្ទុះដោយរលកជាតុអាកាស (ត្រូវមានចំងាយឆ្ងាយជាង)។ ចំងាយកាំរង្វង់អប្បបរិមាគួរមានចំងាយ២៥ម មិនគួរអនុញាតអោយ សាធារណៈជនចូលទៅកាន់តំបន់អសុវត្ថិភាពនេះជាដាច់ខាត នៅពេលកិច្ចប្រតិបត្តិការដោះមីនកំពុងដំណើរការនៅការដ្ឋាន។

នៅពេលមានការចូលមកកន្លែងមានគ្រោះថ្នាក់ដោយជនណាម្នាក់ នោះអ្នកដោះមីនទាំងអស់ត្រូវបញ្ឈប់កិច្ចប្រតិបត្តិការជាបន្ទាន់ បន្លឺសញ្ញាទៅអ្នកផ្សេងទៀតនៅការដ្ឋាន ពិនិត្យកែតម្រូវបញ្ហាគ្រោះថ្នាក់នោះសិន មុននឹងបន្តកិច្ចប្រតិបត្តិការបោសសំអាតមីន។ ចំងាយសុវត្ថិភាពអប្បរិមានេះ មិនយកមកអនុវត្តចំពោះអ្នកមកត្រួតពិនិត្យបច្ចេកទេស ឬអ្នកត្រួតពិនិត្យការដ្ឋានឡើយនៅពេលដែលពួកគេបំពេញការងាររបស់ខ្លួនដែលតម្រូវឲ្យចូលទៅជិតឡើយ។ បទដ្ឋានប្រតិបត្តិការគួរបែងចែកឲ្យដាច់រវាងប្រភេទនៃអ្នកមកទស្សនាចំការមីនរួមមាន អ្នកកាសែត អ្នកបច្ចេកទេស និងភ្ញៀវធម្មតា។

នៅពេលទីតាំងនានានៅការដ្ឋាន តម្រូវឲ្យមានការឆ្លងកាត់ជារឿយៗនូវចំងាយសុវត្ថិភាពខាងក្នុងដោយការប្រើប្រាស់ច្រកឆ្លងកាត់នោះត្រូវពិចារណាលើដំណោះស្រាយផ្សេងៗដើម្បីជំនួស។ បើសិនជាការដ្ឋាននោះតូចល្មម អង្គភាពប្រិតបត្តិករ ត្រូវអនុវត្តកិច្ចប្រតិបត្តិការដោយធ្វើយ៉ាងណាកាត់បន្ថយការរំខានដល់សាធារណៈជន។ បើការដ្ឋានមានទំហំធំ ប្រតិបត្តិករដោះមីន ត្រូវពិចារណាស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋានប៉ូលីស ឬសេវាកម្មបន្ទាន់នានា ឬយោធាដើម្បីកំណត់ដាក់ផ្លាកសញ្ញា និងការត្រួតពិនិត្យលទ្ធភាពនៃការបង្កើតផ្លូវវាង។ បើពុំមានផ្លូវវាងបែបនេះទេ ត្រូវពិចារណាការប្រើប្រាស់ឧបករណ៍ការពារ ឬបង្កើតប្រព័ន្ធត្រួតពិនិត្យការធ្វើចរាចរណ៍ ដែលអនុញ្ញាតឲ្យកិច្ចប្រតិបត្តិការអាចបន្តទៅមុខទៀតបានដោយការអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចឆ្លងកាត់បានតាមពេលកំណត់។

### ៣-៤- តំបន់ត្រួតពិនិត្យ

ត្រូវបង្កើត និងដាក់សញ្ញាសំគាល់ឲ្យបានច្បាស់លាស់នូវតំបន់មួយចំនួន ដើម្បីផ្តល់លទ្ធភាពដល់ផ្នែករដ្ឋបាលអាចត្រួតពិនិត្យការដ្ឋានប្រកបដោយប្រសិទ្ធភាព។ តំបន់ត្រួតពិនិត្យទាំងនេះ ត្រូវស្ថិតនៅក្រៅរង្វង់ចំងាយសុវត្ថិភាពពីតំបន់ដែលមានមីន តំបន់កំពុងប្រតិបត្តិការដោះមីន និងឃ្លាំងផ្ទុករំសេវផ្ទុះ។

### ៣.៤.១. កន្លែងចតរថយន្ត

កន្លែងចតរថយន្តត្រូវជាតំបន់ដែលគេបានដឹងថាមានសុវត្ថិភាព ឬបានបោសសំអាតមីនរួច ព្រមទាំងមានទំហំធំគ្រប់គ្រាន់ សំរាប់ចតរថយន្តរបស់អង្គភាពដោះមីន និងរថយន្តភ្ញៀវ។ ត្រូវដាក់សញ្ញាសំគាល់ និងផ្លាកសញ្ញាអោយបានច្បាស់លាស់នៅតាមព្រំកន្លែងចតរថយន្ត។ កន្លែងចតរថយន្ត ត្រូវចង្អុលបង្ហាញពីទិសដៅទៅកាន់ការដ្ឋានដោះមីន និងកន្លែងពន្យល់សង្ខេបជូនភ្ញៀវ។

លើសពីនេះទៀត ប្រធានចំការមីន ឬអ្នកទទួលខុសត្រូវជំនួស ត្រូវធានាថាគ្រប់រថយន្តទាំងអស់ ត្រូវបានចតដោយបែរមុខទៅរកច្រកចេញ ហើយគ្មានការចតណាមួយដែលរំខានដល់ការចេញដំណើររបស់រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដែលគិតថាប្រើសំរាប់ប្រតិបត្តិការសង្គ្រោះបន្ទាន់នោះឡើយ។ រថយន្តសង្គ្រោះបន្ទាន់ និងរថយន្តសុវត្ថិភាពត្រូវមានកូនសោរនៅជាប់រថយន្តជានិច្ចនៅការដ្ឋានដោះមីន។

### ៣.៤.២. កន្លែងឧទ្ធម្ភាគចក្រចុះចត

បើសិនជាជ្រើសរើសយកការប្រើឧទ្ធម្ភាគចក្រសំរាប់ជំលៀសជនរងគ្រោះ ត្រូវរៀបចំកន្លែងសំរាប់ឧទ្ធម្ភាគចក្រចុះចត មុននឹងចាប់ផ្តើមកិច្ចប្រតិបត្តិការនៅការដ្ឋាន។ ទំហំ និងលំហអាកាសសំរាប់ឧទ្ធម្ភាគចក្រចុះចត ត្រូវរៀបចំឡើងដោយអនុលោមតាមតម្រូវការរបស់អង្គការដែលផ្តល់សេវាសង្គ្រោះជនរងគ្រោះតាមអាកាស។ កន្លែងឧទ្ធម្ភាគចក្រចុះចត មិនត្រូវដាក់នៅជិតតំបន់គ្រោះថ្នាក់ឡើយ ហើយត្រូវពិចារណាពីការចុះ-ឡើង ការគំរាមពីខ្សែអន្ទាក់ ស្លាបកង្ហា និង វត្ថុចំលែកដែលនៅរប៉ាត់រប៉ាយ។ ត្រូវផ្តល់អោយអង្គការដែលផ្តល់សេវាជំលៀសជនរងគ្រោះតាមអាកាសជាមុននូវចំនួនការដ្ឋានដោះមីន និយាមការសំរាប់កន្លែងឧទ្ធម្ភាគចក្រចុះចត និងការពិពណ៌នាផ្សេងៗ (រាប់បញ្ចូលទាំងការដាក់សញ្ញាសំគាល់)។

កន្លែងឧទ្ធម្ភាគចក្រចុះចតត្រូវដាក់សញ្ញាសំគាល់ដែលងាយមើលឃើញ (របស់ទទួលពន្លឺពីគេហើយជះពន្លឺត្រលប់វិញ) ដែលមានទំហំតូចបំផុត២មx២មភ្ជាប់ទៅនឹងដីសំរាប់ឧទ្ធម្ភាគចក្រចុះចត (អង្គការផ្តល់សេវាជំលៀសជនរងគ្រោះតាមអាកាសត្រូវផ្តល់ការណែនាំអំពីការចាត់ចែងផ្នែកសន្តិសុខ)។ ត្រូវដាក់សញ្ញាឲ្យច្បាស់ផងដែរពីការដ្ឋានដោះមីនផ្សេងទៀត ដែលត្រូវទទួលរ៉ាប់រងដោយការសង្គ្រោះនេះ។ ត្រូវរើសយកចេញនូវសំភារៈដែលជ្រុះនៅកន្លែងចុះចតឧទ្ធម្ភាគចក្រ និងពីកន្លែងកាំរង្វង់ដែលស្នើឡើងដោយអង្គការផ្តល់សេវាជំលៀសជនរងគ្រោះតាមអាកាស។ កន្លែងចុះចតឧទ្ធម្ភាគចក្រមិនអាចប្រើសំរាប់ជាកន្លែងចតរថយន្ត ឬកន្លែងរដ្ឋបាលនោះទេ។

ប្រតិបត្តិករដោះមីនត្រូវធានាផងដែរ ក្នុងការបង្ហាត់បុគ្គលិកឲ្យយល់ច្បាស់ពីការឲ្យសញ្ញាបញ្ជាឧទ្ធម្ភាគចក្រចុះចត នៅកន្លែងសំរាប់ឧទ្ធម្ភាគចក្រចុះដោយសុវត្ថិភាព។ បុគ្គលិកទាំងអស់ត្រូវយល់ដឹងពីនីតិវិធីសុវត្ថិភាពនានាសំរាប់ចូលទៅកាន់ ឬធ្វើការងារជាមួយឧទ្ធម្ភាគចក្រ ឧទាហរណ៍ដូចជា បុគ្គលិកទាំងនោះមិនត្រូវស្លៀកពាក់ខោអាវរហែក និង ប្រើសំភារៈដែលមានគំរបជាដើម។ល។

### ៣.៤.៣. កន្លែងរាយការណ៍ និងពន្យល់សង្ខេបជូនភ្ញៀវ

កន្លែងរាយការណ៍ និងពន្យល់សង្ខេបជូនភ្ញៀវ ត្រូវដាក់សញ្ញាសំគាល់អោយបានច្បាស់លាស់ ដោយត្រូវធានាថាស្ថិតនៅក្រៅតំបន់គ្រោះថ្នាក់ដោយសារអំបែងពីការដ្ឋានដោះមីន។

### ៣.៤.៤. បរិក្ខារការពារខ្លួន (PPE)

គ្រប់អ្នកដោះមីន និងភ្ញៀវចូលទៅក្នុងចំការមីននៅពេលកំពុងប្រតិបត្តិការបោសសំអាតមីន ដាច់ខាតត្រូវពាក់បរិក្ខារការពារខ្លួនដោយអនុលោមតាមស្តង់ដាជំពូក១១ ជាចាំបាច់។

### ៣.៤.៥. ផ្លូវសុវត្ថិភាព

ពេលខ្លះនៅចំការមីនទាមទារឲ្យអ្នកដោះមីនធ្វើការនៅកន្លែងជាច្រើនផ្សេងៗគ្នា។ ក្នុងករណីនេះ ប្រតិបត្តិករដោះមីនត្រូវរៀបចំបង្កើតនូវផ្លូវសុវត្ថិភាព ដែលបានបោសសំអាតមីនរួច ដើម្បីផ្តល់ផ្លូវចេញ-ចូលទៅកាន់ការដ្ឋានដោះមីន និងបរិវេណជុំវិញការដ្ឋានដោះមីន។ ផ្លូវដែលដោះមីនរួច ត្រូវដាក់សញ្ញាសំគាល់ និងរៀបចំកត់ត្រាក្នុងឯកសារដូចមានបញ្ជាក់នៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។ ផ្លូវសុវត្ថិភាពត្រូវមានទំហំធំគ្រប់គ្រាន់ សំរាប់ផ្តល់សុវត្ថិភាពក្នុងការធ្វើដំណើរ និងដឹកជញ្ជូនសំភារៈទៅកាន់ការដ្ឋានដោះមីន។ ផ្លូវសុវត្ថិភាពសំរាប់ការសង្គ្រោះបន្ទាន់ ត្រូវមានទំហំធំទូលាយសំរាប់សុវត្ថិភាពស្របតាមនីតិវិធីសង្គ្រោះបន្ទាន់។ ផ្លូវសុវត្ថិភាពមិនត្រូវមានទំហំទទឹងតូចជាង២ម៉ែត្រឡើយ។

### ៣.៤.៦. ការសង្គ្រោះបឋម

ការដ្ឋានដោះមីននីមួយៗ ត្រូវរៀបចំអោយមានកន្លែងសង្គ្រោះបន្ទាន់ដោយត្រូវចាត់ចែង និងបំពាក់សំភារៈទៅតាមអនុសាសន៍ដូចមានចែងនៅក្នុងស្តង់ដា១០.៤០។ កន្លែងសង្គ្រោះបន្ទាន់ត្រូវ ៖

ក. ជាកន្លែងដែលអាចសំគាល់បាន និងដាក់សញ្ញាយ៉ាងច្បាស់លាស់
ខ. បំពាក់សំភារៈអោយបានសមស្របសំរាប់សង្គ្រោះបន្ទាន់ ព្រមទាំងមានការផ្គត់ផ្គង់បរិក្ខារពេទ្យ
គ. ត្រូវអោយបុគ្គលិកពេទ្យដែលមានលក្ខណៈសម្បត្តិ និងមានបទពិសោធន៍គ្រប់គ្រាន់ប្រចាំការនៅការដ្ឋាន
ឃ.រៀបចំផ្លូវចេញ-ចូលទៅកាន់តំបន់បោសសំអាតមីន និងផ្លូវចេញ-ចូលទៅកាន់រថយន្តសង្គ្រោះឲ្យបានងាយស្រួល។ ប្រសិនបើគ្មានទេ ត្រូវរក្សាផ្លូវសុវត្ថិភាពដែលមានទំហំ២ម ដោយពុំត្រូវមានសំរាម ឬឧបសគ្គដោយដើមឈើឡើយ ដើម្បីងាយស្រួលក្នុងការជន្លៀសជនរងគ្រោះ
ង. ជាទូទៅនៅគ្រប់ការដ្ឋានទាំងអស់ ត្រូវមានរថយន្តសង្គ្រោះបន្ទាន់ដែលបំពាក់សំភារៈគ្រប់គ្រាន់។ ក្នុងករណីពុំមានទេ អាចប្រើរថយន្តសង្គ្រោះបន្ទាន់/រថយន្តសុវត្ថិភាពសំរាប់ទទួលរ៉ាប់រងការដ្ឋានលើសពីមួយបានប្រសិនបើៈ
- រថយន្តសង្គ្រោះបន្ទាន់នោះអាចមកដល់ការដ្ឋាននៅក្នុងរយៈពេល ១០ នាទី
- អ្នកបើកបររថយន្តសង្គ្រោះបន្ទាន់ស្គាល់ច្បាស់ពីទីតាំងនៃការដ្ឋាននីមួយៗ ព្រមទាំងធ្លាប់មកទីកន្លែងទាំងនោះពីមុន
- គ្រប់ការដ្ឋានដោះមីនដែលត្រូវប្រើរថយន្តសង្គ្រោះបន្ទាន់នោះ មិនត្រូវនៅឆ្ងាយជាង៧គមឡើយ
- ពេលមានឧប្បទ្ទវហេតុ/គ្រោះថ្នាក់ដោយដោះមីនកើតឡើង ហើយរថយន្តសង្គ្រោះបន្ទាន់ត្រូវបានប្រើនោះគ្រប់ការដ្ឋានដែលត្រូវប្រើរថយន្តនោះត្រូវផ្អាកប្រតិបត្តិការសិន ទំរាំមានរថយន្តសង្គ្រោះបន្ទាន់ផ្សេងទៀតដែលមានបំពាក់សំភារៈគ្រប់គ្រាន់មកជំនួស ឬរថយន្តដំបូងត្រលប់មកកន្លែងដើមវិញ។ មិនអាចអនុញ្ញាតឲ្យការដ្ឋានដោះមីន ណាមួយប្រតិ

បត្តិការដោយពុំមានរថយន្តសង្គ្រោះបន្ទាន់បំពាក់សំភារៈគ្រប់គ្រាន់ និងបុគ្គលិកជំនាញខាងពេទ្យនៅប្រចាំការបានឡើយ។

- អ្នកបើកបររថយន្តសង្គ្រោះបន្ទាន់ត្រូវស្គាល់ និងធ្លាប់បើកទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត

**៣.៤.៧. កន្លែងឈប់សំរាក**

ត្រូវរៀបចំកន្លែងឈប់សំរាកឲ្យបានត្រឹមត្រូវ ដោយដាក់សញ្ញាសំគាល់យ៉ាងច្បាស់លាស់ សំរាប់អ្នកដោះមីននៅការដ្ឋានលើកលែងតែការដ្ឋាននោះ ត្រូវបានឈប់សំរាកនៅពេលនោះ។ កន្លែងសំរាកត្រូវស្ថិតនៅក្រៅតំបន់គ្រោះថ្នាក់ដោយអំបែង និងបំពាក់ដោយសំភារៈសំរាប់ការពារអាកាសធាតុមិនល្អ។ ត្រូវមានកេះចាក់ខ្សាច់/ទឹកមួយ សំរាប់ដាក់កំទេចបារីនៅកន្លែងសំរាក។ ត្រូវរៀបចំឲ្យមានកន្លែងបត់ជើងនៅកន្លែងសំរាកផងដែរ ប្រសិនបើពុំចាំបាច់ដើរទៅរកកន្លែង រដ្ឋបាលទេនោះ។

**៣.៤.៨. កន្លែងទុកដាក់គ្រឿងផ្ទុះ**

គ្រឿងផ្ទុះ ឬគ្រាប់មីន និង/ឬគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសំភារៈដែលមានគ្រោះថ្នាក់ អាចត្រូវបានរក្សាទុកនៅការដ្ឋានដោះមីនបាន។ គ្រឿងផ្ទុះដែលត្រូវប្រើប្រាស់នៅក្នុងដំណើរការដោះមីន ត្រូវរក្សាទុកនៅក្នុងកុងទីន័រ ដែលបានអនុញ្ញាតឲ្យប្រើសំរាប់ប្រភេទ និងចំនួនគ្រឿងផ្ទុះដែលត្រូវរក្សាទុកនោះ ហើយត្រូវស្ថិតនៅក្រៅតំបន់គ្រោះថ្នាក់ដោយអំបែងនៅការដ្ឋានដោះមីន (សូមអានស្តង់ដាជំពូក-០៤ ស្តង់ដាសំរាប់ធ្វើកេះ និងឃ្លាំងតូចសំរាប់ទុកគ្រឿងផ្ទុះដែលត្រូវប្រើប្រាស់នៅក្នុងដំណើរការដោះមីន)។ ចំងាយសុវត្ថិភាពនឹងត្រូវកាត់បន្ថយប្រសិនបើមានការរៀបចំដាក់របាំងការពារសមស្របដូចមានចែងនៅក្នុងតារាងសុវត្ថិភាព។ ប្រសិនបើកន្លែងទុកដាក់គ្រឿងផ្ទុះមិនអាចធ្វើនៅក្រៅតំបន់ជះអំបែងបានទេនោះ ត្រូវរៀបចំឲ្យមានការការពារឲ្យបានគ្រប់គ្រាន់។

ក្នុងករណីដែលមិនអាចរកកុងទីន័រដូចមានបញ្ញត្តិក្នុងស្តង់ដានេះបាន ប្រតិបត្តិករដោះមីន ត្រូវទទួលខុសត្រូវក្នុងការផ្តល់វិធានការណ៍សុវត្ថិភាពនានាដូចជា (វិធានការណ៍ការពារ ចំងាយសុវត្ថិភាព សន្តិសុខ។ល។) រាប់បញ្ចូលទាំងកត្តាចាំបាច់នានាសំរាប់ការពារបរិស្ថាន ដោយអនុលោមតាមការណែនាំរបស់អ្នកផលិតគ្រឿងផ្ទុះនោះ។ ការទុកដាក់បែបនេះ គឺជាវិធានការណ៍ទុកដាក់បណ្តោះអាសន្នប៉ុណ្ណោះ។

**៤.ឧប្បទ្ទវហេតុ និងគ្រោះថ្នាក់ដោយការដោះមីន**

នីតិវិធីសំរាប់ឆ្លើយតបទៅនឹងឧប្បទ្ទវហេតុ និងគ្រោះថ្នាក់ដោយការដោះមីន ត្រូវបង្កើតឡើង និងរៀបចំជាឯកសារដូចជាបទដ្ឋានប្រតិបត្តិការដែរ ដោយដាក់បញ្ចូលដូចខាងក្រោមៈ

ក. ត្រូវរៀបចំឲ្យមានអង្គការចាត់តាំងដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងឧប្បទ្ទហេតុ ឬគ្រោះថ្នាក់ដោយការដោះមីន រាប់បញ្ចូលទាំងនីតិវិធី ការបណ្តុះបណ្តាល ការឆ្លើយតបទៅនឹងសញ្ញា និងចំនួនអ្នករងគ្រោះច្រើននាក់ ការជួយជនរងគ្រោះឲ្យមានសុវត្ថិភាព ពីគ្រឿងចក្រ ពីសុនខ ការរៀបចំឲ្យមានបរិក្ខារ និងសំភារៈសង្គ្រោះ (សូមអានស្តង់ដា១០.៤០)។

ខ. នីតិវិធីសំរាប់ការស៊ើបអង្កេតដោយសុវត្ថិភាព ការវិភាគ និងការកែតម្រូវបន្ទាប់ពីមានឧប្បទ្ទវហេតុ គ្រោះថ្នាក់ដោយការដោះមីន (មានចែងនៅក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាជំពូក៥)។

## ៥.កាតព្វកិច្ច និងការទទួលខុសត្រូវ

### ៥.១. អាជ្ញាធរមីន

អាជ្ញាធរមីនត្រូវរៀបចំគោលការណ៍ច្បាប់ បង្កើត និងថែរក្សាឯកសារនីតិវិធីសំរាប់សុវត្ថិភាព និងសុខុមាលភាពវិជ្ជាជីវៈនៅការដ្ឋានដោះមីន។ ឯកសារនីតិវិធីទាំងនោះ ត្រូវដាក់បញ្ចូលនូវៈ

ក. ស្តង់ដានៃផ្លាកសញ្ញាសុវត្ថិភាពសំរាប់ប្រើប្រាស់លើរថយន្តសង្គ្រោះបន្ទាន់

ខ. ស្តង់ដាក្នុងការឆ្លើយតបបន្ទាន់ និងនីតិវិធីសំរាប់ជំលៀសជនរងគ្រោះនៅការដ្ឋានដោះមីន

គ. នីតិវិធីសំរាប់ធ្វើរបាយការណ៍ និងស៊ើបអង្កេតឧប្បទ្ទហេតុ និងគ្រោះថ្នាក់ដោយសារដោះមីន

### ៥.២. ប្រតិបត្តិករដោះមីន

ប្រតិបត្តិករដោះមីនត្រូវបង្កើត និងថែរក្សាឯកសារបទដ្ឋានប្រតិបត្តិការ ដែលស្របទៅតាមស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា និងស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ។

ប្រតិបត្តិករដោះមីនត្រូវជូនដំណឹងពីការផ្លាស់ប្តូរបទដ្ឋានប្រតិបត្តិការមកអាជ្ញាធរមីន។ អាជ្ញាធរមីននឹងធ្វើការសំរេចចិត្តថាតើការផ្លាស់ប្តូរនោះ ទាមទារឲ្យធ្វើការវាយតំលៃលើឯកសារ និងនៅតាមការដ្ឋានឡើងវិញឬយ៉ាងណា។ លក្ខណៈ វិនិច្ឆ័យសំរាប់ធ្វើវិសោធនកម្មលើបទដ្ឋានប្រតិបត្តិការ មានចែងនៅក្នុងស្តង់ដាជំពូក០២។

### ៥.៣. អ្នកដោះមីន

អ្នកដោះមីនទាំងអស់ត្រូវអនុវត្តដូចខាងក្រោមៈ

ក. ត្រូវថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពអ្នកដទៃនៅក្នុងការដ្ឋាន

ខ. ប្រតិបត្តិការតាមការណែនាំដែលបានចែងសំរាប់ការអនុវត្តន៍ និងសុវត្ថិភាពផ្ទាល់ខ្លួន ជាពិសេសរាល់ការណែនាំដែលបានសរសេរនៅក្នុងបទដ្ឋានប្រតិបត្តិការ

គ. ប្រតិបត្តិតាមសេចក្តីណែនាំ និងច្បាប់ទំលាប់របស់ជាតិ ស្តីពីការអនុវត្តន៍ និងសុវត្ថិភាពនៅការដ្ឋាន

ឃ.រាយការណ៍ជូនថ្នាក់ដឹកនាំជាបន្ទាន់ នូវសភាពការណ៍ដែលជឿជាក់ថាអាចនឹងមានគ្រោះថ្នាក់ដល់ការដ្ឋាន ដែលពួកគេមិនអាចកែសម្រួលបាន

ង.ត្រូវលើកជាសំនួរលើការណែនាំនានា ដែលខ្លួនជឿថានឹងអាចនាំឲ្យមានគ្រោះថ្នាក់ដល់ខ្លួន

# ឧបសម្ព័ន្ធ ក
(ជាគំរូ)
# ចំងាយសុវត្ថិភាពសំរាប់តំបន់គ្រោះថ្នាក់ដោយមីនខ្យល់ និង មីនជះអំបែង

## ១.ទូទៅ

ការគណនាចំងាយគ្រោះថ្នាក់មានភាពស្មុគស្មាញបំផុត និងទាមទារការពិចារណាពីកត្តានៃកំរិតចំងាយដូចខាងក្រោមៈ

ក. ការបែងចែកគ្រោះថ្នាក់ និងការចែកលំដាប់នៃគ្រោះថ្នាក់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលអាចមាននៅការដ្ឋានដោះមីន

ខ វិធានការណ៍ការពាររាប់បញ្ចូលទាំងឯកសារបទដ្ឋានប្រតិបត្តិការ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា និងស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ

គ. ការការពារដែលផ្តល់ឲ្យដោយកំរិតព្រៃស្មៅ ស្ថានភាពភូមិសាស្ត្រដី (ទាប ឬខ្ពស់) រចនាសម្ព័ន្ធនៅជុំវិញការដ្ឋាន និងការការពារដែលអាចធ្វើទៅបានចំពោះអ្នកដោះមីន ភ្ញៀវ និងសាធារណៈជន

ឃ. លក្ខខ័ណ្ឌអាកាសធាតុ

ង. កត្តាបរិស្ថាននានា

## ២.ចំងាយសុវត្ថិភាពដែលបានកំណត់

បើពុំមានការវាយតំលៃពីគ្រោះថ្នាក់លំអិត និងការគណនាចំងាយសុវត្ថិភាពធ្វើឡើងដោយអ្នកជំនាញកំទេចគ្រាប់យុទ្ធភ័ណ្ឌទេនោះ ត្រូវអនុវត្តចំងាយសុវត្ថិភាពនៅក្នុងតារាងដូចខាងក្រោមៈ

**២-១- ចំងាយសុវត្ថិភាពនៅការដ្ឋានដោះមីន**

| **សកម្មភាព** | **គម្លាតពីគ្នាគិតជាម៉ែត្រ** |
|---|---|
| ច្រើនជាងមួយពួក | ២៥ |
| អ្នកដោះមីនធ្វើការនៅក្នុងផ្លូវជាមួយគ្នា | ២៥ |
| អ្នកដោះមីន និងម៉ាស៊ីនកាត់ស្មៅ | ៥០ |
| អ្នកដោះមីន និងគ្រឿងយន្តបោកដី | ១០០ |
| ផ្លូវចេញ-ចូល និងតំបន់សុវត្ថិភាព | ២៥ |
| ចំងាយសុវត្ថិភាពរវាងសុនខហិតរកមីន | ២៥ |
| កន្លែងចតរថយន្ត ក្រុមពេទ្យ និងការដ្ឋានបោសសំអាតមីន | ១០០ |

**ចំណាំ១:**ចំងាយសុវត្ថិភាពពីពួកមួយទៅពួកមួយទៀតនិងអ្នកដោះមីនអាចត្រូវកាត់បន្ថយដោយការប្រើប្រាស់នូវការសិក្សាវាយតំលៃពីកំរិតគ្រោះថ្នាក់នៅក្នុងចំការមីនដែលមានតែមីនជះអំបែង។

**ចំណាំ២:**ករណីប្រើវិធីសាស្ត្រដោះមីនដោយប្រើមនុស្សពីរនាក់នៅក្នុងជួរតែមួយនៅចំការមីនដែលមានតែមីនខ្យល់ក្រោយពីធ្វើការសិក្សាវាយតំលៃរួចនោះចំងាយពីអ្នកដោះមីនម្នាក់ទៅអ្នកដោះមីនម្នាក់ទៀតអាចត្រូវកាត់បន្ថយ

| |
|---|
| **ចំណាំ៣**:ដោយប្រើការសិក្សាវាយតំលៃ និង/ឬប្រើរបាំងការពារចំងាយសុវត្ថិភាពអាចត្រូវបានកាត់បន្ថយ<br>**ចំណាំ៤**:ចំងាយសុវត្ថិភាពនៅក្នុងតារាងនេះ គួរអនុវត្តចំពោះការដ្ឋានដែលគេបានវាយតំលៃថាមានតែមីនខ្យល់ប្រឆាំងមនុស្សតែប៉ុណ្ណោះ។ ចំងាយសុវត្ថិភាពសំរាប់មីនផ:អំបែង គឺមានចំងាយឆ្ងាយជាងមីនខ្យល់ និងអាស្រ័យទៅលើទំហំគ្រោះថ្នាក់ពិត។<br>**ចំណាំ៥**:សូមអានស្តង់ដា០៧.៥០ ចំងាយសុវត្ថិភាពសំរាប់ទុកដាក់រំសេវផ្ទុះនៅការដ្ឋាន |

**តួលេខទី ១: ចំងាយសុវត្ថិភាពសំរាប់ការដ្ឋានដោះមីនដែលមានមីនខ្យល់ប្រឆាំងមនុស្ស**

### ២-២- ចំងាយសុវត្ថិភាពសំរាប់ការកំទេចគ្រាប់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

| ចំងាយសុវត្ថិភាពអប្បបរិមា សំរាប់ការកំទេចគ្រាប់ | |
|---|---|
| **ប្រភេទនៃគ្រាប់** | **កន្លែងវាលលំហ គិតជាម៉ែត្រ** |
| មីនប្រឆាំងមនុស្ស-ផ:ខ្យល់ | ១០០ |
| មីនប្រឆាំងមនុស្សលោតផ:អំបែង ផ:អំបែងតាមទិសដៅ | ២០០/៥០០ |
| មីនប្រឆាំងរថគ្រោះ-ផ:ខ្យល់ | ៣០០/១០០០ |
| មីនប្រឆាំងរថគ្រោះ សេបធាត (កំសួលដែលបាញ់ចេញពីសេបធាតអាចហោះបាន១៨០០ម នៅក្នុងលំហ) | ១៨០០ |
| មីន (Off Route Mine) | ១០០០ |
| គ្រាប់កាំភ្លើងត្បាល់ ទំហំ៨២មម | ៥០០ |
| គ្រាប់កាំភ្លើងធ្លោង ទំហំ៨០មម | ៥០០ |
| គ្រាប់កាំភ្លើងធ្លោង ទំហំ១៦០មម | ៨០០ |
| គ្រាប់កាំភ្លើងធ្លោង ទំហំលើសពី១៦០មម | ១០០០ |
| គ្រាប់រ៉ុកែត ទំហំ៨៨មម | ៥០០ |
| គ្រាប់បែកដៃ និងគ្រាប់បែកបាញ់ឡង់ | ៣០០ |

| |
|---|
| **ចំណាំ១**: រំសេវផ្ទុះដែលកប់ដីមានទំងន់១០គក ត្រូវមានចំងាយសុវត្ថិភាព៥០០ម។ ត្រូវបន្ថែមចំងាយសុវត្ថិភាព១០០មទៀត បើមានរំសេវផ្ទុះទំងន់១០គកបន្ថែម។<br>**ចំណាំ២**: ប្រតិបត្តិករដោះមីនទាំងអស់ ត្រូវស្វែងរកការណែនាំពីអ្នកជំនាញឯកទេសខាងកំទេចគ្រាប់យុទ្ធភ័ណ្ឌ ដើម្បីកំណត់ចំងាយសុវត្ថិភាពសំរាប់គ្រាប់រំសេវដែលពុំមានក្នុងតារាងខាងលើ។<br>ចំងាយសុវត្ថិភាពទាំងអស់ត្រូវកំណត់អោយបានច្បាស់លាស់នៅក្នុងបទដ្ឋានប្រតិបត្តិការ។<br>**ចំណាំ៣**:ត្រូវមានវិធានការការពារ ដើម្បីកាត់បន្ថយចំងាយសុវត្ថិភាព |

**តួលេខទី២: ចំងាយសុវត្ថិភាពអប្បបរិមាសំរាប់ការកំទេចគ្រាប់**

# ឧបសម្ព័ន្ធ ខ

## (ជាពត៌មាន)

## ការរៀបចំសំរាប់ភ្ញៀវមកទស្សនកិច្ចនៅការដ្ឋានដោះមីន

### ១.ទូទៅ

សកម្មភាពដោះមីន ទាក់ទាញភ្ញៀវពីសហគមន៍អ្នកផ្តល់ជំនួយ រដ្ឋាភិបាល មន្ត្រីនានា រួមទាំងក្រុមត្រួតពិនិត្យអាជ្ញាធរមីន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាដើម។ ត្រូវលើកទឹកចិត្តដល់ភ្ញៀវមកទស្សនាការដ្ឋានដោះមីនទាំងនោះ ព្រោះពួកគេអាចជួយផ្តល់យោបល់ណែនាំ និងជួយស្វែងរកធនធានជាថវិកាសំរាប់វិស័យសកម្មភាពកំចាត់មីន។

### ២.បទដ្ឋានប្រតិបត្តិការ

ប្រតិបត្តិករដោះមីន ត្រូវរៀបចំ និងថែរក្សាឯកសារនីតិវិធីសំរាប់ភ្ញៀវដែលមកទស្សនកិច្ចការដ្ឋានដោះមីន។ បទដ្ឋានប្រតិបត្តិការនេះ ត្រូវដាក់បញ្ចូលនូវៈ

**ក. នីតិវិធីសំរាប់បង្កើត និងថែរក្សាសញ្ញានានាៈ**

-ផ្តល់ការព្រមានចំពោះភ្ញៀវ ឬសាធារណៈជនកុំអោយចូលទៅក្នុងតំបន់គ្រោះថ្នាក់ដោយមីនខ្យល់ ឬមីនជះអំបែង
- នាំផ្លូវភ្ញៀវទៅកាន់កន្លែងចតរថយន្តដែលមានសុវត្ថិភាព
- នាំផ្លូវភ្ញៀវទៅកាន់កន្លែងពន្យល់សង្ខេប ឬកន្លែងរាយការណ៍

**ខ.ពន្យល់សង្ខេបពីសុវត្ថិភាព រួមជាមួយពត៌មានលើ:**

-ការរៀបចំការដ្ឋាន ប្រព័ន្ធដាក់សញ្ញាសំគាល់សុវត្ថិភាព និងបំរាមផ្សេងៗទៀតដូចជាការហាមមិនឲ្យដើរហេតរហូត ការប្រើប្រាស់សំភារៈដែលអាចជាគ្រោះថ្នាក់នៃរលកធាតុអាកាស (ទូរសព្ទចល័ត វិទ្យុ។ល។) និងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចដទៃទៀត ឬម៉ាស៊ីនថត។ នៅពេលបើកកិច្ចប្រតិបត្តិការសុនខហិតរកមីន ត្រូវបន្ថែមព័ត៌មានហាមឃាត់នានាស្តីពីការចូលទៅកាន់ឲ្យចំណី និងនាំសុនខលេងជាដើម។
- តម្រូវការអោយពាក់ឧបករណ៍ការពារខ្លួន
- សកម្មភាពដែលត្រូវអនុវត្តក្នុងពេលមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ដោយសារដោះមីន

**គ. ភាពទទួលខុសត្រូវលើសំណងក្នុងករណីមានគ្រោះថ្នាក់**

### ៣.ការធានារ៉ាប់រង

ប្រតិបត្តិករដោះមីនត្រូវមានការធានារ៉ាប់រងដល់ភាគីទីបីដើម្បីរ៉ាប់រងពីគ្រោះថ្នាក់ចំពោះភ្ញៀវដែលមកទស្សនាការដ្ឋានដោះមីន។ ការធានារ៉ាប់រងនេះ មិនត្រឹមតែទទួលខុសត្រូវដល់ប្រតិបត្តិករដោះមីនប៉ុណ្ណោះទេ តែត្រូវទទួលខុសត្រូវដល់និយោជិកផងដែរ។ ការធានារ៉ាប់រងសំរាប់និយោជិកនៃប្រតិបត្តិករដោះមីន មានចែងក្នុងស្តង់ដាជំពូក០៩ (សុវត្ថិភាព និងសុខមាលភាពតម្រូវការទូទៅ)។

ភ្នំពេញ ថ្ងៃទី 27 ខែ ៧ ឆ្នាំ ២០០៧

អគ្គលេខាធិការ

សម សុត្ថា